# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១ អនក្រ.បក

## អនុក្រឹត្យ

## ស្តីពី

## ការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស-រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១០០/១០ ចុះថ្ងៃទី៣ ខែ វិច្ឆិកាឆ្នាំ ២០០០ ប្រកាសអោយប្រើច្បាប់ ស្តីពីការគ្រប់គ្រង លើការប្រកបវិជ្ជាជីវៈឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ជំនួយវេជ្ជសាស្ត្រ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការ បង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំ ឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង សុខាភិបាល
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ១៩៩២ ស្តីពីការបង្កើត និង ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា និង សិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

# សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់ពីលក្ខខណ្ឌ និង លក្ខណៈវិនិច្ឆ័យ នៃការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ដែលអនុវត្តសម្រាប់គ្រឹះស្ថានសិក្សាសាធារណៈ និង ឯកជននៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា ២.-**

អនុក្រឹត្យនេះមានវិសាលភាពគ្របដណ្តប់លើការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល គ្រប់ជំនាញនិងគ្រប់កម្រិត ។

## ជំពូកទី ២

## លក្ខខណ្ឌនៃការបណ្តុះបណ្តាលវិស័យសុខាភិបាល

**មាត្រា ៣.-**

គ្រឹះស្ថានសិក្សា ដែលមានបំណងបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ត្រូវគោរព និង បំពេញអោយបាននូវលក្ខខណ្ឌ ដូចខាងក្រោម :

- ផែនការយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍកម្មវិធីបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល
- រចនាសម្ព័ន្ធគ្រប់គ្រង និង លក្ខខណ្ឌក្នុងការជ្រើសតាំងអ្នកគ្រប់គ្រង កម្មវិធីបណ្តុះបណ្តាល
- កម្មវិធីសិក្សាលំអិត រួមមានខ្លឹមសារ និង ការរៀបចំនៃកម្មវិធីសិក្សានោះ
- សាស្ត្រាចារ្យ រួមមាន គុណវុឌ្ឍិ បទពិសោធន៍បង្រៀន និង បទពិសោធន៍ វិជ្ជាជីវៈ
- បន្ទប់សិក្សា បន្ទប់បង្ហាញគ្រាប់ បន្ទប់ពិសោធន៍ និងបណ្ណាល័យ ព្រមទាំង សៀវភៅសិក្សា និង មូលដ្ឋានសម្ភាររូបវន្ត សម្រាប់បម្រើឱ្យការសិក្សា និងការស្រាវជ្រាវ
- គ្រឹះស្ថានសម្ព័ន្ធ សំរាប់ទ្រទ្រង់កម្មសិក្សាដូចជា មន្ទីរពេទ្យ គ្លីនីកពហុព្យាបាល មជ្ឈមណ្ឌល វិទ្យាស្ថាន មន្ទីរពិសោធន៍ រោងចក្រ សហគ្រាសឱសថ
- សំណុំឯកសារលំអិតផ្សេងទៀត

**មាត្រា ៤.-**

គ្រឹះស្ថានសិក្សាឯកជន ត្រូវតំកល់ប្រាក់ធានាជាអចិន្ត្រៃយ៍នៅធនាគារជាតិនៃកម្ពុជា ។ ប្រាក់តំកល់នោះ ត្រូវស្មើនឹង ៥០ ភាគរយ នៃថវិកាផែនការ បី ឆ្នាំ ដើម្បីធានានិរន្តរភាព នៃការបណ្តុះបណ្តាល ។

**មាត្រា ៥.-**

ចំនួននិស្សិតដែលត្រូវជ្រើសរើសចូលរៀនតាមមុខជំនាញ ព្រមទាំង សូចនាករអនុវត្តន៍ សម្រាប់លក្ខខណ្ឌ និង លក្ខណៈវិនិច្ឆ័យ ដែលចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ត្រូវកំណត់ដោយប្រកាសរួមរបស់ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា ។

## ជំពូកទី ៣
## លក្ខខណ្ឌសំរាប់ការចូលរៀន និង ការទទួលស្គាល់គុណវុឌ្ឍិ

**មាត្រា ៦.-**

ការចូលរៀន និងការប្រលងបញ្ចប់ការសិក្សានៅ គ្រប់កម្រិត និងគ្រប់ជំនាញ ក្នុងវិស័យសុខាភិបាលត្រូវមាន ការប្រលងថ្នាក់ជាតិ ។ បេក្ខជនដែលអាចប្រលងចូលរៀនថ្នាក់ឧត្តមសិក្សាបានត្រូវមាន វិញ្ញាបនប័ត្រ ថ្នាក់ឆ្នាំសិក្សា មូលដ្ឋាន ។ បេក្ខជនដែលអាចប្រលងចូលរៀនថ្នាក់មធ្យមសិក្សាបានត្រូវមានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិ ។ ចំពោះកំរិត និង ជំនាញសុខាភិបាលផ្សេងទៀត ត្រូវគោរពតាមលក្ខខណ្ឌរបស់ ក្រសួងសុខាភិបាល និង ក្រសួង អប់រំ យុវជន និង កីឡា ។ ការប្រលងថ្នាក់ជាតិ ដើម្បីទទួលស្គាល់គុណវុឌ្ឍិ អ្នកបញ្ចប់ថ្នាក់ឧត្តមសិក្សានិងអ្នកបញ្ចប់ថ្នាក់មធ្យមសិក្សា ត្រូវធ្វើឡើងបន្ទាប់ ពីការប្រឡងបញ្ចប់ការសិក្សាដោយជោគជ័យពីគ្រឹះស្ថានបណ្តុះបណ្តាល ។

**មាត្រា ៧.-**

គណៈកម្មាធិការប្រលងថ្នាក់ជាតិ ត្រូវតែងតាំងឡើងដោយរាជរដ្ឋាភិបាល ដែលមានសមាសភាព ដូចខាងក្រោម:

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី — ប្រធាន
- រដ្ឋលេខាធិការក្រសួងសុខាភិបាល ទទួលបន្ទុកការងារបណ្តុះបណ្តាល — អនុប្រធាន
- រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និង កីឡា ទទួលបន្ទុកឧត្តមសិក្សា — អនុប្រធាន
- អគ្គលេខាធិការ នៃ គណៈកម្មការធិការ ទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា — សមាជិក
- សាកលវិទ្យាធិការនៃសាកលវិទ្យាល័យ ឬ នាយកគ្រឹះស្ថានសិក្សាសាម៉ី — សមាជិក
- តំណាងគណៈវិជ្ជាជីវៈ ពាក់ព័ន្ធ — សមាជិក
- ប្រធានក្រុមប្រឹក្សាភិបាលសមាគមគ្រឹះស្ថានឧត្តមសិក្សានៅកម្ពុជា — សមាជិក

គណៈកម្មាធិការប្រលងថ្នាក់ជាតិនេះ មានលេខាធិការដ្ឋានមួយ ជាជំនួយការ ដែលមានសមាសភាពមកពីនាយកដ្ឋាន ឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា និង នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្សនៃក្រសួងសុខាភិបាល ។ លេខាធិការដ្ឋាននេះមានទីតាំងនៅនាយកដ្ឋានឧត្តមសិក្សានៃក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា ៨.-**

គណៈកម្មាធិការប្រលងថ្នាក់ជាតិ ត្រូវរៀបចំ យន្តការនៃការប្រលង គ្រប់កំរិត និង គ្រប់ជំនាញ ដើម្បីធានាអោយការប្រលង មានភាពត្រឹមត្រូវ យុត្តិធម៌ និង តម្លាភាព ជាពិសេសការប្រើប្រាស់ប្រធានវិញ្ញាសារប្រលងតែមួយ សំរាប់គ្រឹះស្ថានសិក្សារដ្ឋ និង គ្រឹះស្ថានសិក្សាឯកជន ។

**មាត្រា ៩.-**

គណៈកម្មាធិការប្រលងថ្នាក់ជាតិនេះ មានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

## ជំពូកទី ៤

## គន្លង និង កំរិតនៃការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

### ក. ផ្នែកឧត្តមសិក្សា

**មាត្រា ១០.-**

**១. ផ្នែកវិជ្ជាជីវៈ ថែទាំ ពិនិត្យ ព្យាបាលជម្ងឺ**

**១.១ វេជ្ជសាស្ត្រ**

១.១.១ ថ្នាក់ បរិញ្ញាប័ត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ សិក្សារយៈពេលយ៉ាងតិច៦ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មានចំនួនក្រេឌីតសរុប យ៉ាងតិច ២១០ក្រេឌីត ។

១.១.២ ថ្នាក់ វេជ្ជបណ្ឌិតទូទៅ ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាប័ត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ យ៉ាងតិច ២ឆ្នាំ មានចំនួន ក្រេឌីត សរុបយ៉ាងតិច ៥៤ ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.១.៣ ថ្នាក់ វេជ្ជបណ្ឌិតឯកទេស ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាប័ត្រវិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឬ ពីថ្នាក់វេជ្ជបណ្ឌិតទូទៅ យ៉ាងតិច ៣ឆ្នាំ មានចំនួនក្រេឌីត យ៉ាងតិច៦០ក្រេឌីត រួមទាំងនិក្ខេបបទ ។

**១.២ ទន្តវេទសាស្ត្រ**

១.២.១ ថ្នាក់ បរិញ្ញាប័ត្រវិទ្យាសាស្ត្រទន្តវេទសាស្ត្រ សិក្សារយៈពេល យ៉ាងតិច ៥ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន មានចំនួនក្រេឌីតសរុប យ៉ាងតិច ១៨០ក្រេឌីត ។

១.២.២ ថ្នាក់ ទន្តបណ្ឌិតទូទៅ ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាប័ត្រវិទ្យាសាស្ត្រទន្តវេទសាស្ត្រ យ៉ាងតិច ២ឆ្នាំ មាន ចំនួន ក្រេឌីតយ៉ាងតិច ៥៤ ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.២.៣ ថ្នាក់ ទន្តបណ្ឌិតឯកទេស ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាប័ត្រវិទ្យាសាស្ត្រទន្តវេទសាស្ត្រ ឬ ពីថ្នាក់ទន្តបណ្ឌិតទូទៅ យ៉ាងតិច ៣ឆ្នាំ មានចំនួនក្រេឌីត យ៉ាងតិច ៦០ ក្រេឌីតរួមទាំងនិក្ខេបបទ ។

**១.៣ ឱសថសាស្ត្រ**

១.៣.១ ថ្នាក់ បរិញ្ញាប័ត្រឱសថសាស្ត្រ សិក្សារយៈពេល យ៉ាងតិច ៥ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ ឆ្នាំសិក្សាមូលដ្ឋានមានចំនួន ក្រេឌីតសរុប យ៉ាងតិច១៨០ក្រេឌីត ។

១.៣.២ ថ្នាក់ ឱសថបណ្ឌិតទូទៅ ត្រូវសិក្សាបន្ថែមពីថ្នាក់បរិញ្ញាប័ត្រឱសថសាស្ត្រ យ៉ាងតិច ២ឆ្នាំ មានចំនួនក្រេឌីតសរុបយ៉ាងតិច ៥៤ក្រេឌីត រួមទាំងនិក្ខេបបទ ។

១.៣.៣ ថ្នាក់ ឱសថបណ្ឌិតឯកទេស ត្រូវសិក្សាបន្ថែមពីថ្នាក់ បរិញ្ញាប័ត្រឱសថសាស្ត្រ ឬ ថ្នាក់ឱសថបណ្ឌិតទូទៅ យ៉ាងតិច ៣ឆ្នាំ មានចំនួនក្រេឌីតសរុបយ៉ាងតិច ៦០ ក្រេឌីត រួមទាំងនិក្ខេបបទ ។

**១.៤ ជំនួយវេជ្ជសាស្ត្រ**

១.៤.១ ថ្នាក់ បរិញ្ញាប័ត្រគិលានុបដ្ឋាក ថ្នាក់ បរិញ្ញាប័ត្រឆ្មប និង ថ្នាក់ បរិញ្ញាប័ត្រផ្នែកជំនួយវេជ្ជសាស្ត្រដទៃទៀត ត្រូវសិក្សារយៈពេល យ៉ាងតិច ៤ឆ្នាំ ដោយរាប់បញ្ចូលថ្នាក់ ឆ្នាំសិក្សាមូលដ្ឋាន មានចំនួនក្រេឌីតសរុប យ៉ាងតិច ១៣០ក្រេឌីត រួមទាំងសារណា ។

១.៤.២ ថ្នាក់ បរិញ្ញាប័ត្រគិលានុបដ្ឋាក ត្រូវសិក្សាបន្ថែមក្រោយពីថ្នាក់បរិញ្ញាប័ត្ររង រយៈពេលយ៉ាងតិច ៣ ឆមាស មានចំនួនក្រេឌីតសរុប យ៉ាងតិច ៤៥ ក្រេឌីត រួមទាំងសារណា ។

**២. ផ្នែកសុខភាពសាធារណៈ និង ស្រាវជ្រាវ**

២.១ ថ្នាក់ បរិញ្ញាប័ត្រជាន់ខ្ពស់ សុខភាពសាធារណៈ ត្រូវសិក្សាបន្ថែមពីថ្នាក់បរិញ្ញាប័ត្រ វិទ្យាសាស្ត្រវេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ បរិញ្ញាប័ត្រគិលានុបដ្ឋាក បរិញ្ញាប័ត្រឆ្មប ឬ បរិញ្ញាប័ត្រជំនួយវេជ្ជសាស្ត្រដ៏ទៃទៀត យ៉ាងតិចរយៈពេល ២ឆ្នាំ មានចំនួនក្រេឌីតសរុប យ៉ាងតិច ៥៤ ក្រេឌីត ។

២.២ ថ្នាក់ បណ្ឌិតវិទ្យាសាស្ត្រ តាមមុខជំនាញនិមួយៗ រួមមាន សុខភាពសាធារណៈ វេជ្ជសាស្ត្រ ឱសថសាស្ត្រ ទន្តវេទនសាស្ត្រ ជំនួយវេជ្ជសាស្ត្រ ត្រូវកំណត់ដោយប្រកាសរួមរបស់ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និងកីឡា ។

**ខ- ផ្នែកមធ្យមសិក្សា**

**មាត្រា ១១.-**

**ផ្នែកវិជ្ជាជីវៈ ថែទាំ ជម្ងឺ និង ជំនួយវេជ្ជសាស្ត្រ**

១. ថ្នាក់ បរិញ្ញាប័ត្ររង ផ្នែកគិលានុបដ្ឋាក ផ្នែកឆ្មប និងផ្នែកជំនួយវេជ្ជសាស្ត្រ ដទៃទៀត ត្រូវសិក្សារយៈពេលយ៉ាងតិច ៣ឆ្នាំ មានក្រេឌីតសរុបចំនួនយ៉ាងតិច១០០ក្រេឌីត ។

២. ថ្នាក់ បរិញ្ញាប័ត្ររងឯកទេស ផ្នែកគិលានុបដ្ឋាក ផ្នែកឆ្មប និងផ្នែកជំនួយវេជ្ជសាស្ត្រ ដទៃទៀត ត្រូវសិក្សាបន្ថែមក្រោយពីថ្នាក់បរិញ្ញាប័ត្ររង រយៈពេល យ៉ាងតិចពី ២ ទៅ ៣ ឆមាស មានក្រេឌីតសរុបចំនួន ៣៥ ទៅ ៤៥ ក្រេឌីត តាមឯកទេសនីមួយ ៗ ។

**មាត្រា ១២.-**

លក្ខខណ្ឌ និង លក្ខណវិនិច្ឆ័យ ស្តីពី គន្លង និង ការិតគ្រប់មុខជំនាញនៃការបណ្តុះបណ្តាល ក្នុងវិស័យសុខាភិបាល មានចែងលំអិតក្នុងប្រកាសរួមរបស់ ក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូកទី ៥

## លក្ខខណ្ឌ និង ការទទួលស្គាល់គុណភាពអប់រំនៃគ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាល

**មាត្រា ១៣.-**

គ្រឹះស្ថានឧត្តមសិក្សាវិស័យសុខាភិបាលត្រូវគោរពទៅតាមស្តង់ដាអប្បបរមាដូចមានចែងក្នុងមាត្រា ៩ នៃព្រះរាជក្រឹត្យលេខនស-រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែមិនា ឆ្នាំ២០០៣ស្តីពី ការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា និង លក្ខខណ្ឌនៃការបណ្តុះបណ្តាលក្នុង វិស័យសុខាភិបាលដែលមានចែង ក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ ។

**មាត្រា ១៤.-**

គ្រឹះស្ថានមធ្យមសិក្សាវិស័យសុខាភិបាល ត្រូវគោរពទៅតាមលក្ខខណ្ឌនៃការបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល ដែលមានចែងក្នុងមាត្រា ៣ នៃអនុក្រឹត្យនេះ។

**មាត្រា ១៥.-**

ការទទួលស្គាល់គុណភាពអប់រំរបស់គ្រឹះស្ថានឧត្តមសិក្សាវិស័យសុខាភិបាល ជាសមត្ថកិច្ចរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

## ជំពូកទី ៦

## លក្ខខណ្ឌនៃការផ្អាកនិងការបញ្ឈប់ការទទួលស្គាល់គ្រឹះស្ថានបណ្តុះបណ្តាលក្នុងវិស័យសុខាភិបាល

**មាត្រា ១៦.-**

រាជរដ្ឋាភិបាលធ្វើការសម្រេចផ្អាកជាបណ្តោះអាសន្ន ឬ ការបញ្ឈប់ជាស្ថាពរត្រូវធ្វើឡើងចំពោះគ្រឹះស្ថានឧត្តមសិក្សា ឬគ្រឹះស្ថានមធ្យមសិក្សាណា ដែលមិនគោរពតាមមាត្រា ៣ មាត្រា ៦ និងមាត្រា ១៣ នៃអនុក្រឹត្យនេះ។

ការសំរេចឱ្យផ្អាកបណ្តោះអាសន្ន ឬ ការបញ្ឈប់ជាស្ថាពរត្រូវធ្វើឡើងតាមសំណើពីក្រសួងសុខាភិបាល និង ក្រសួងអប់រំ យុវជន និង កីឡា ។

## ជំពូកទី ៧

## អន្តរប្បញ្ញត្តិ

**មាត្រា ១៧.-**

គ្រឹះស្ថានបណ្តុះបណ្តាលដែលកំពុងដំណើរការសព្វថ្ងៃត្រូវរៀបចំកែលំអអោយបានតាមលក្ខខណ្ឌ ដូចមានកំណត់ក្នុងអនុក្រឹត្យនេះ លើកលែងតែ និយាមសំរាប់គ្រូ និង អគារសិក្សា ដែលត្រូវបំពេញអោយបានក្នុងរយៈពេលយ៉ាងយូរ ៥ឆ្នាំ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ចំពោះកម្មវិធីសិក្សាដែលកំពុងអនុវត្ត ត្រូវរៀបចំកែសំរួលអោយបានតាមកម្មវិធីសិក្សាជាតិដើម្បីអនុវត្តប្រើចាប់ពីឆ្នាំសិក្សា ២០០៧-២០០៨ តទៅ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ១៨.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងខ្លឹមសារនៃអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ១៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ពន្ធ័ គ្រប់គ្រឹះស្ថានបណ្តុះបណ្តាលវិស័យសុខាភិបាលទាំងអស់ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០០៧

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

**កន្លែងទទួល:**

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ដូចមាត្រា ១៩
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ